# និយ័តករគណនេយ្យនិងសវនកម្ម

## ព្រឹត្តិបត្រព័ត៌មានប្រចាំខែឧសភា ឆ្នាំ២០២៥

លេខ:០០៥


សេចក្តីសង្ខេបព័ត៌មាន និងព្រឹត្តិការណ៍សំខាន់ៗប្រចាំខែឧសភា របស់និយ័តករគណនេយ្យ និងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ រួមមានដូចខាងក្រោម៖

## ព័ត៌មានថ្មីៗ


កិច្ចប្រជុំបច្ចេកទេស សូមអាននៅទំព័រ.................... ១
វគ្គបណ្តុះបណ្តាលស្តីពី សូមអាននៅទំព័រ................១
កិច្ចប្រជុំ សូមអាននៅទំព័រ .................................២
កិច្ចប្រជុំបច្ចេកទេស សូមអាននៅទំព័រ....................២
កិច្ចប្រជុំពិភាក្សា សូមអាននៅទំព័រ.........................៣
សិក្ខាសាលាផ្សព្វផ្សាយ សូមអាននៅទំព័រ................៣
សិក្ខាសាលាស្តីពី សូមអាននៅទំព័រ..........................៤
កិច្ចប្រជុំស្តីពី សូមអាននៅទំព័រ..............................៤
ជួបពិភាក្សា សូមអាននៅទំព័រ..................................៤
សិក្ខាសាលាផ្សព្វផ្សាយ សូមអាននៅទំព័រ..................៥
ជួបពិភាក្សា សូមអាននៅទំព័រ..................................៥
កិច្ចប្រជុំពិភាក្សា សូមអាននៅទំព័រ.........................៥
វគ្គបណ្តុះបណ្តាលស្តីពី សូមអាននៅទំព័រ................៦
សិក្ខាសាលាផ្សព្វផ្សាយ សូមអាននៅទំព័..................៦
វគ្គបណ្តុះបណ្តាលស្តីពី សូមអាននៅទំព័..................៧
កិច្ចប្រជុំពិភាក្សា សូមអាននៅទំព័រ.........................៧
សិក្ខាសាលាផ្សព្វផ្សាយច្បាប់ សូមអាននៅទំព័រ..........៨
បទបង្ហាញស្តីពី សូមអាននៅទំព័រ.............................៨
សិក្ខាសាលាផ្សព្វផ្សាយ សូមអាននៅទំព័រ..................៩
វគ្គបណ្តុះបណ្តាលស្តីពី សូមអាននៅទំព័រ................៩
កិច្ចប្រជុំក្រុមការងារ សូមអាននៅទំព័រ.....................៩
សិក្ខាសាលារួមគ្នាស្តីពី សូមអាននៅទំព័រ............. ១០
ជំនួបសម្តែងការគួរសម សូមអាននៅទំព័រ.............១០
សិក្ខាសាលាផ្សព្វផ្សាយ សូមអាននៅទំព័រ.............១១
វគ្គបណ្តុះបណ្តាលស្តីពី សូមអាននៅទំព័រ.............១១
កិច្ចប្រជុំពិភាក្សា សូមអាននៅទំព័រ......................១១
ប្រធានបទអនាគត សូមអាននៅទំព័រ.....................១២


## កិច្ចប្រជុំបច្ចេកទេសនៃអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ




១.កាលពីថ្ងៃសុក្រ ៦ កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២ ខែឧសភា គ.ស.២០២៥ លោក ទឹម សត្យា អនុប្រធានទទួលបន្ទុករួមនាយកដ្ឋានកិច្ចការទូទៅ តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ចាន់រិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយមន្ត្រីជំនាញ បានអញ្ជើញចូលរួមកិច្ចប្រជុំបច្ចេកទេសនៃអង្គភាព ក្រោម ឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព ដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សានៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំនិងមន្ត្រីជំនាញ និយ័តករ និងអង្គភាពក្រោមឱវាទ អ.ស.ហ.។ កិច្ចប្រជុំដើម្បីពិនិត្យនិងផ្តល់យោបល់លើរបៀបវារៈចំនួន២រួមមាន៖សេចក្តីព្រាងផែនការសកម្មភាពបីឆ្នាំរំកិល(២០២៥-២០២៧) របស់និយ័តករធានារ៉ាប់រងកម្ពុជានិងសេចក្តីព្រាងប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណនិងការគ្រប់គ្រងអាជីវកម្មទ្រព្យឪដីថលរបស់និយ័តករមូលបត្រកម្ពុជា។

## វគ្គបណ្តុះបណ្តាលស្តីពី "ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម"



២.កាលពីថ្ងៃចន្ទ ៩កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៥ ខែឧសភា គ.ស.២០២៥ និយ័តករគណនេយ្យនិងសវនកម្ម សហការជាមួយអគ្គនាយកដ្ឋានពន្ធដារនិងក្រុមហ៊ុន ឌីអេស្វស៊ី បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម"(CFIRS for SMEs) វគ្គទី២ ជូនដល់មន្ត្រីនៃអគ្គនាយកដ្ឋានពន្ធដារ រយៈពេល ៥ថ្ងៃ នៅអគារ ៣៤៥។ វគ្គបណ្តុះបណ្តាលនេះប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ចាន់រិន**អគ្គនាយក នៃនិយ័តករគណនេយ្យ

និងសវនកម្ម **ឯកឧត្តមបណ្ឌិត កែន សម្បត្តិ** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ និង **លោក សាយ សុខខេង** អគ្គនាយកក្រុមហ៊ុន ឌីអេស្វស៊ី ដែរមានសិក្ខាកាមចូលរួមចំនួន៦០នាក់។ វគ្គបណ្តុះបណ្តាលនេះរៀបចំឡើងក្នុងគោលដៅបញ្ជ្រាបការយល់ដឹង និងសិក្សាលម្អិត លើបច្ចុប្បន្នភាពលក្ខខណ្ឌតម្រូវនៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម ដែលជាមូលដ្ឋានក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដូចមានចែងក្នុងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ។

## កិច្ចប្រជុំក្រុមការងារជំរុញការអនុវត្តយុទ្ធសាស្រ្តនានា របស់ ន.គ.ស.



៣.កាលពីថ្ងៃចន្ទ ៩កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៥ ខែឧសភា គ.ស.២០២៥ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម បានដឹកនាំកិច្ចប្រជុំក្រុមការងារជំរុញការអនុវត្តយុទ្ធសាស្រ្តនានា របស់ ន.គ.ស. ក្នុងគោលបំណង ពិនិត្យ តាមដាន និងវាយតម្លៃ ការអនុវត្តយុទ្ធសាស្រ្តនានាដែលបានដាក់ចេញដោយ ន.គ.ស. ដើម្បីធានាបានថាការអនុវត្តយុទ្ធសាស្រ្ត ប្រកបដោយប្រសិទ្ធិភាពខ្ពស់។

## កិច្ចប្រជុំបច្ចេកទេសនៃអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ




៤.កាលពីថ្ងៃចន្ទ ៩កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៥ ខែឧសភា គ.ស.២០២៥ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយមន្ត្រីជំនាញ បានអញ្ជើញចូលរួមកិច្ចប្រជុំបច្ចេកទេសនៃអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិត ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនិយ័តករ និងអង្គភាពក្រោមឱវាទ អ.ស.ហ.។ កិច្ចប្រជុំមានគោលបំណង ដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងប្រកាស ស្តីពីការបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធ របស់និយ័តករមូលបត្រកម្ពុជា។

© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

## កិច្ចប្រជុំពិភាក្សាលើការងាររៀបចំវេទិកាជាតិគណនេយ្យឆ្នាំ២០២៥




៥.កាលពីថ្ងៃអង្គារ ១០កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៦ ខែឧសភា គ.ស.២០២៥ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម បានបន្តដឹកនាំកិច្ចប្រជុំពិភាក្សាលើការងាររៀបចំវេទិកាជាតិគណនេយ្យឆ្នាំ២០២៥ តាមប្រព័ន្ធអនឡាញ ដែលមានការចូលរួមពីថ្នាក់ដឹកនាំ នៃន.គ.ស. ថ្នាក់ដឹកនាំវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា លោកប្រធាន ACCA ប្រចាំកម្ពុជា ព្រមទាំងក្រុមការងារដែលប្រព្រឹត្តិទៅនាដើមខែកញ្ញា ឆ្នាំ២០២៥ ខាងមុខ។

## សិក្ខាសាលាផ្សព្វផ្សាយស្តីពី "កាតព្វកិច្ចគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ" ជូនដល់ក្រុមហ៊ុនអភិវឌ្ឍអចលនវត្ថុ ក្រុមហ៊ុនផ្តល់សេវាកម្មអចលនវត្ថុ និងក្រុមហ៊ុនបញ្ចាំនិងប្រាតិភោគដោយអនុប្បទាន



៦.កាលពីថ្ងៃអង្គារ ១០កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៦ ខែឧសភា គ.ស.២០២៥ និយ័តករគណនេយ្យនិងសវនកម្ម សហការជាមួយនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "កាតព្វកិច្ចគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ" ជូនដល់ក្រុមហ៊ុនអភិវឌ្ឍអចលនវត្ថុ ក្រុមហ៊ុនផ្តល់សេវាកម្មអចលនវត្ថុ និងក្រុមហ៊ុនបញ្ចាំនិងប្រាតិភោគដោយអនុប្បទានដែលទទួលបានអាជ្ញាបណ្ណ ពីនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ។ សិក្ខាសាលានេះប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម ព្រមទាំងមានការអញ្ជើញចូលរួមពី **ឯកឧត្តម ជូ វណ្ណា:** អគ្គនាយក នៃនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ អមដោយថ្នាក់ដឹកនាំ និងមន្ត្រី ជាពិសេសវត្តមានរបស់ក្រុមហ៊ុនអភិវឌ្ឍអចលនវត្ថុ ក្រុមហ៊ុនផ្តល់សេវាកម្មអចលនវត្ថុនិងក្រុមហ៊ុនបញ្ចាំ ចំនួន២៩០នាក់។

## សិក្ខាសាលាស្តីពីការត្រៀមលក្ខណៈសម្រាប់ ការរៀបចំថវិកាឆ្នាំ២០២៦



៧.កាលពីថ្ងៃសុក្រ ១៣កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៩ ខែឧសភា គ.ស.២០២៥ លោក ទឹម សត្យា អនុប្រធានទទួលបន្ទុករួមនាយកដ្ឋានកិច្ចការទូទៅ តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ៃ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយមន្ត្រីជំនាញ បានអញ្ជើញចូលរួមសិក្ខាសាលាស្តីពីការត្រៀមលក្ខណៈសម្រាប់ការរៀបចំថវិកាឆ្នាំ២០២៦ ផ្ទៃក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការនិងជាប្រធានក្រុមការងារថវិកាកម្រិតថ្នាក់ដឹកនាំអង្គភាពថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

## កិច្ចប្រជុំស្តីពីការបូកសរុបវឌ្ឍនភាពការងារប្រចាំត្រីមាសទី១ ឆ្នាំ២០២៥



៨.កាលពីថ្ងៃ ចន្ទ ១រោច ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី១២ ខែឧសភា គ.ស.២០២៥ និយ័តករគណនេយ្យនិងសវនកម្ម បានរៀបចំកិច្ចប្រជុំស្តីពីការបូកសរុបវឌ្ឍនភាពការងារប្រចាំត្រីមាសទី១ ឆ្នាំ២០២៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ៃ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ លោក លោកស្រី អគ្គនាយករង ថ្នាក់ដឹកនាំ និងមន្ត្រីក្រោមឱវាទ ន.គ.ស.។

## ជួបពិភាក្សាជាមួយវិទ្យាស្ថានហិរញ្ញវត្ថុនិងគណនេយ្យ




៩.កាលពីថ្ងៃសុក្រ ១៣កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៩ ខែឧសភា គ.ស.២០២៥ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ៃ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម លោកស្រី នាន បូនី អគ្គនាយករង អមដោយថ្នាក់ដឹកនាំនិងមន្ត្រីជំនាញ បានជួបពិភាក្សាជាមួយវិទ្យាស្ថានហិរញ្ញវត្ថុនិងគណនេយ្យ។ កិច្ចប្រជុំនេះដើម្បីពិភាក្សាលើការស្នើសុំកិច្ចសហការរវាងនិយ័តករគណនេយ្យនិងសវនកម្ម និងវិទ្យាស្ថានហិរញ្ញវត្ថុនិងគណនេយ្យ ក្នុងការទទួលកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា ទៅបណ្តុះបណ្តាលនៅវិទ្យាស្ថានហិរញ្ញវត្ថុនិងគណនេយ្យ។

## សិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការដាក់ឱ្យ អនុវត្តចំណូលសារពើពន្ធរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា តាមមូលដ្ឋានបង្គរ"



១០.កាលពីថ្ងៃសុក្រ ១៣ កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៩ ខែឧសភា គ.ស.២០២៥ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម មន្ត្រីជំនាញនៃ នាយកដ្ឋានបច្ចេកទេស បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការដាក់ឱ្យអនុវត្តចំណូលសារពើពន្ធរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា តាមមូលដ្ឋានបង្គរ" ក្រោមអធិបតីភាព លោក វ៉ូ វណ្ណា ប្រធាននាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៅសណ្ឋាគារអេមព្រីសអង្គរ ខេត្តសៀមរាប។ សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងអំពីនីតិវិធីនៃការដាក់ឱ្យអនុវត្តចំណូលសារពើពន្ធតាមមូលដ្ឋានបង្គរស្របតាមយុទ្ធសាស្ត្រស្តីពីការអនុវត្តស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរនៅកម្ពុជា ដំណាក់កាលទី២ "គណនេយ្យមូលដ្ឋានសាច់ប្រាក់កែសម្រួល ២០២៥-២០២៧"។

## ជួបពិភាក្សាជាមួយជំនាញការរបស់សហភាពអឺរ៉ុប



១១.កាលពីថ្ងៃសុក្រ ១៣ កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៩ ខែឧសភា គ.ស.២០២៥ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី ឯកឧត្តម ប៊ូ ថារិន អគ្គនាយកនិយ័តករគណនេយ្យនិងសវនកម្ម លោកស្រី ពេជ្រ ម៉ានីឡា អនុប្រធាននាយកដ្ឋានបច្ចេកទេស និងមន្ត្រីជំនាញ ជួបពិភាក្សាជាមួយជំនាញការរបស់សហភាពអឺរ៉ុប ដើម្បីត្រួតពិនិត្យពាក់កណ្តាលអាណត្តិនៃការអនុវត្តផែនការសកម្មភាពរួមដំណាក់កាលទី៤ (CAP-4) ក្នុងគោលដៅតម្រង់ទិសការអនុវត្ត CAP-4 ឱ្យកាន់តែមានប្រសិទ្ធភាព និងត្រៀមលក្ខខណ្ឌចាំបាច់ និងវិធានការនានា សម្រាប់ការអនុវត្តជាមូលដ្ឋាននូវថវិកាព័ត៌មានសមិទ្ធកម្មនៅឆ្នាំ២០២៦ ដូចមានចែងក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣ ព្រមទាំងសម្រួចទិសដៅកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស ទិសដៅកែទម្រង់ប្រព័ន្ធគណនេយ្យសាធារណៈសម្រាប់រយៈពេល៣ឆ្នាំខាងមុខ។

## កិច្ចប្រជុំពិភាក្សាលើការចាត់ប្រភេទក្រុមហ៊ុនសវនកម្មដែលទទួលខុសត្រូវជាសាធារណៈ



១២.កាលពីថ្ងៃសុក្រ ១៣កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៩ ខែឧសភា គ.ស.២០២៥ នៅបន្ទប់ប្រជុំធំ អគារ "គ" នៃទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លោកស្រី នាន បូនី អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយថ្នាក់ដឹកនាំ និងមន្ត្រីជំនាញ បានដឹកនាំកិច្ចប្រជុំពិភាក្សា លើការចាត់ប្រភេទក្រុមហ៊ុនសវនកម្មដែលទទួលខុសត្រូវជាសាធារណៈដែលជាក្រុមហ៊ុនសវនកម្មដែលទទួលបានការទទួលស្គាល់ឬនីតិសម្បទាពីនិយ័តករធានារ៉ាប់រងកម្ពុជា និងនិយ័តករបរធនបាលកិច្ច។ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពី តំណាងវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា តំណាងនិយ័តករធានារ៉ាប់រងកម្ពុជា និងតំណាងនិយ័តករបរធនបាលកិច្ច។

© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

## វគ្គបណ្តុះបណ្តាលស្តីពី "ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម




១៣.កាលពីថ្ងៃចន្ទ ៨រោច ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី១៩ ខែឧសភា គ.ស.២០២៥ និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ សហការជាមួយអគ្គនាយកដ្ឋានពន្ធដារ និងក្រុមហ៊ុន ឌីអេស្វស៊ី រៀបចំវគ្គបណ្តុះបណ្តាលស្តីពី "ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម" វគ្គទី៣ ជូនដល់មន្ត្រីនៃអគ្គនាយកដ្ឋានពន្ធដារ រយៈពេល៥ថ្ងៃនៅអគារ ៣៤៥។ វគ្គបណ្តុះបណ្តាលនេះប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម **ឯកឧត្តមបណ្ឌិត កែន សម្បត្តិ** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ និង **លោក សាយ សុខខេង** អគ្គនាយកក្រុមហ៊ុនឌីអេស្វស៊ី ដែរមានសិក្ខាកាមចូលរួមចំនួន៦០នាក់។ វគ្គបណ្តុះបណ្តាលនេះរៀបចំឡើងក្នុងគោលដៅបញ្ជ្រាបការយល់ដឹងនិងសិក្សាលម្អិត លើបច្ចុប្បន្នភាពលក្ខខណ្ឌតម្រូវនៃស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម ដែលជាមូលដ្ឋានក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដូចមានចែងក្នុងច្បាប់ស្តីពីគណនេយ្យនិងសវនកម្មនិងបទប្បញ្ញត្តិពាក់ព័ន្ធ។

## សិក្ខាសាលាផ្សព្វផ្សាយស្តីពីការពង្រឹងប្រសិទ្ធភាព នៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ




១៤.កាលពីថ្ងៃចន្ទ ៨រោច ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៩ ខែឧសភា គ.ស.២០២៥ លោក ទឹម សត្យា អនុប្រធានទទួលបន្ទុករួមនាយកដ្ឋានកិច្ចការទូទៅ តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយមន្ត្រីជំនាញបានអញ្ជើញចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពីការពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់អង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រព្រឹត្តទៅនៅខេត្តសៀមរាប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មាធិការបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋប្រចាំ កសហវ.។

## វគ្គបណ្តុះបណ្តាលស្តីពីស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ




១៥.កាលពីថ្ងៃពុធ ១០រោច ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២១ ខែឧសភា គ.ស.២០២៥ និយ័តករ គណនេយ្យ និងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ វគ្គទី២ រយៈពេល៣ថ្ងៃ នៅអាគារ ៣៤៥ ក្រោមអធិបតីភាព លោកស្រី នាន បូនី អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយថ្នាក់ដឹកនាំ មន្ត្រី និងសិក្ខាកាមចំនួន២០នាក់។ ក្នុងនោះ លោកស្រីអគ្គនាយករង បានលើកឡើងថាវគ្គបណ្តុះបណ្តាលនិងសិក្សាលម្អិតទៅលើចំនួនសំខាន់ៗរួមមាន៖ លក្ខខណ្ឌតម្រូវតាមច្បាប់ស្តីពីគណនេយ្យនិងសវនកម្មនិងបទប្បញ្ញត្តិពាក់ព័ន្ធ, គោលបំណងនិងលក្ខខណ្ឌចាំបាច់, ចំណូល-ចំណាយ, គណនីធនាគារនិងសាច់ប្រាក់, កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុព័ត៌មានចាំបាច់, កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ ព័ត៌មានជាជម្រើសនិងការរៀបចំអន្តរកាល។

## កិច្ចប្រជុំពិភាក្សាជាមួយតំណាង EMILE WOOLF INTERNATIONAL ( EWI )




១៦.កាលពីថ្ងៃព្រហស្បតិ៍ ១១រោច ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២២ ខែឧសភា គ.ស.២០២៥ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម និងជាអនុប្រធានប្រចាំការគណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា លោក ហុង ពិសិដ្ឋ ប្រធានអនុគណៈកម្មាធិការអភិវឌ្ឍកម្មវិធីសិក្សា បានដឹកនាំអនុប្រធាន និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា ប្រជុំពិភាក្សាជាមួយតំណាង EMILE WOOLF INTERNATIONAL ( EWI ) ដើម្បីពិភាក្សាទាក់ទងនឹងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា តាមប្រព័ន្ធអនឡាញ។

## សិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ



១៧.កាលពីថ្ងៃព្រហស្បតិ៍ ១១រោច ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២២ ខែឧសភា គ.ស.២០២៥ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពង់ពី **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម , លោកស្រី តាំង ឈីវហុង ប្រធានការិយាល័យនីតិកម្មនិងដោះស្រាយវិវាទ និងមន្ត្រីជំនាញបានចូលរួមសិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្រោមអធិបតីភាព លោក ង៉ោ ដាឡែន អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន អ.ស.ហ.នៅខេត្តក្រចេះ។ សិក្ខាសាលានេះមានវត្តមានចូលរួមពីតំណាងអង្គភាពក្រោមឱវាទ អ.ស.ហ. តំណាងមន្ទីរ អង្គភាពពាក់ព័ន្ធ សហគ្រាស និងសិស្សនិស្សិតចំនួន១៨០នាក់។

## បទបង្ហាញស្តីពី "ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា លេខ ១២ ស្តីពីសន្និធិ" ក្នុងវគ្គបណ្តុះបណ្តាលប្រកាសស្តីពី "ការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យនៃសន្និធិ"



១៨.កាលពីថ្ងៃសុក្រ ១២ រោច ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៣ ខែឧសភា គ.ស.២០២៥ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយកនិយ័តករគណនេយ្យនិងសវនកម្ម មន្ត្រីជំនាញនៃនាយកដ្ឋានបច្ចេកទេសបានចូលរួមជាវាគ្មិនធ្វើបទបង្ហាញស្តីពី "ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា លេខ ១២ ស្តីពីសន្និធិ" ក្នុងវគ្គបណ្តុះបណ្តាលប្រកាសស្តីពី "ការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យនៃសន្និធិ" ដែលរៀបចំដោយអគ្គនាយកដ្ឋានរតនាគារជាតិ ដោយមានការចូលរួមពីតំណាងមកពីក្រសួងស្ថាប័នចំនួន១០ នៅសាលប្រជុំជាន់ផ្ទាល់ដីនៃអគ្គនាយកដ្ឋានរតនាគារជាតិ (អគារថ្មី) សរុប៥០នាក់។

## សិក្ខាសាលាផ្សព្វផ្សាយស្តីពី "ភាតព្វកិច្ចគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ" សម្រាប់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ នៅសាលរដ្ឋបាលខេត្តស្វាយរៀង



១៩.កាលពីថ្ងៃសុក្រ ១២រោច ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៣ ខែឧសភា គ.ស.២០២៥ និយ័តករគណនេយ្យ និងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "កាតព្វកិច្ចគណនេយ្យនិងសវនកម្ម និង បទប្បញ្ញត្តិពាក់ព័ន្ធ" សម្រាប់សហគ្រាសនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញខេត្តស្វាយរៀង។ សិក្ខាសាលានេះប្រព្រឹត្តទៅក្រោមអធិបតីភាព លោកស្រី នាន បូនី អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម។ សិក្ខាសាលានេះក៏មានការអញ្ជើញចូលរួមពី លោក សុខ រស់ អភិបាលរង និងមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រី សមាជិកសមាជិកា ព្រមទាំងវត្តមានរបស់តំណាងសហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ចំនួន១៧០នាក់។

## វគ្គបណ្តុះបណ្តាលស្តីពី "បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត និងបច្ចេកវិទ្យាហិរញ្ញវត្ថុ"




២០.កាលពីថ្ងៃ ចន្ទ ១៥រោច ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២៦ ខែឧសភា គ.ស.២០២៥ និយ័តករគណនេយ្យ និងសវនកម្ម បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត និងបច្ចេកវិទ្យាហិរញ្ញវត្ថុ" ក្រោមអធិបតីភាព លោក ជា ចាន់ថា អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម ជូនដល់ថ្នាក់ដឹកនាំ នឹងមន្ត្រីក្រោមឱវាទ ន.គ.ស។ វគ្គសិក្សានេះនឹងជួយឱ្យថ្នាក់ដឹកនាំ និងមន្ត្រីរបស់និយ័តករគណនេយ្យនិងសវនកម្ម អាចពង្រឹងសមត្ថភាពបន្ថែមទាក់ទងនឹងការវិភាគទិន្នន័យ, បច្ចេកវិទ្យាហិរញ្ញវត្ថុដែលអាចជួយធ្វើឱ្យការអនុវត្តការងារប្រចាំថ្ងៃកាន់តែមានប្រសិទ្ធភាពនិងការធ្វើស្វ័យប្រវត្តិកម្មលើការងារដដែលៗ ជំនួយដល់ការវិភាគទិន្នន័យ និងជួយគាំទ្រដល់ការសម្រេចចិត្តកាន់តែប្រសើរឡើងនៅក្នុងវិជ្ជាជីវៈគណនេយ្យនិងហិរញ្ញវត្ថុ។

## កិច្ចប្រជុំក្រុមការងាររៀបចំ កម្មវិធីសន្និសីទគណនេយ្យករជំនាញអាស៊ានលើកទី៤



២១.កាលពីថ្ងៃពុធ ២កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២៨ ខែឧសភា គ.ស.២០២៥ និយ័តករគណនេយ្យ និងសវនកម្ម បានរៀបចំកិច្ចប្រជុំក្រុមការងាររៀបចំកម្មវិធីសន្និសីទគណនេយ្យករជំនាញអាស៊ានលើកទី៤ ក្នុងគោលបំណងដើម្បីតាមដានវឌ្ឍភាពការងារ ដែរនឹងរៀបចំឡើងនៅក្នុងខែកក្កដានាពេលខាងមុខ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក និយ័តករគណនេយ្យនិងសវនកម្ម អមដោយលោកស្រី អគ្គនាយករង និងមានការអញ្ជើញចូលរួមពីលោក-លោកស្រីប្រធាន និងអនុប្រធាននាយកដ្ឋាននិងមន្ត្រីក្រោមឱវាទ នៃ ន.គ.ស. ដែលជាក្រុមការងារទទួលបន្ទុករៀបចំ និងសម្របសម្រួលសន្និសីទ។

© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

## សិក្ខាសាលារួមគ្នាស្តីពី "បច្ចុប្បន្នភាពស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ អន្តរជាតិ"



២២.កាលពីថ្ងៃព្រហស្បតិ៍ ៣កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៩ ខែឧសភា គ.ស.២០២៥ និយ័តករគណនេយ្យនិងសវនកម្ម និង CPA Australia សហការណ៍ជាមួយក្រុមហ៊ុន KPMG (Cambodia) Ltd បានរៀបចំសិក្ខាសាលារួមគ្នាស្តីពី "បច្ចុប្បន្នភាពស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ" ក្រោមអធីបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ី ថារិន** អគ្គនាយកនៃ និយ័តករគណនេយ្យនិងសវនកម្ម លោកស្រី Priya Terumalay ប្រធានប្រចាំតំបន់អាស៊ីអាគ្នេយ៍នៃស្ថាប័ន CPA Australia និង លោក ង៉ែ ហ៊ុយ ដៃគូជាន់ខ្ពស់និងជាប្រធានផ្នែកសវនកម្មនៃក្រុមហ៊ុន KPMG (Cambodia) Ltd នៅអគារ Oakwood Premier Phnom Penh។ សិក្ខាសាលានេះរៀបចំឡើងក្នុងគោលបំណងបញ្ជ្រាបការយល់ដឹងបន្ថែមអំពីបច្ចុប្បន្នភាពថ្មីៗ នៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ (IFRS) ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (IASB) និងការអនុវត្តស្តង់ដាទាំងនេះនៅក្នុងប្រទេសកម្ពុជាឱ្យកាន់តែមានភាពទូលំទូលាយនិងប្រកបដោយប្រសិទ្ធភាព។

## ជំនួបសម្តែងការគួរសម និងពិភាក្សាលើក្របខណ្ឌយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ



២៣.កាលពីថ្ងៃព្រហស្បតិ៍ ៣កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៩ ខែឧសភា គ.ស.២០២៥ នៅបន្ទប់ប្រជុំធំនៃទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លោកស្រី នាន បូនី អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ី ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយថ្នាក់ដឹកនាំនិងមន្ត្រីជំនាញ បានចូលរួមអម **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្នុងជំនួបសម្តែងការគួរសមនិងពិភាក្សាលើក្របខណ្ឌយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុនិងការកសាងសមត្ថភាពធនធានក្នុងវិស័យជាមួយតំណាងសមាគមន៍គណនេយ្យករជំនាញ ACCA។

## សិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥



© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

២៤.កាលពីថ្ងៃព្រហស្បត្តិ៍ ៣កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៥ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម លោក ឈាង ឆេងហាន អនុប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាព អមដោយមន្ត្រីជំនាញបានចូលរួមសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍ ស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ (IDP) ក្នុងឆ្នាំ២០២១-២០២៣ ក្រោម អធិបតីភាព ឯកឧត្តម ជា វុទ្ធី អគ្គលេខាធិការ គណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ.វ.ក./ក.អ.ក នៅសណ្ឋាគាររីវ៉ាខេត្តព្រះសីហនុ។

## វគ្គបណ្តុះបណ្តាលស្តីពី ស្តង់ដាររបាយការណ៍ទាក់ទង នឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម




២៥.កាលពីព្រហស្បតិ៍ ៣កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៥ និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម" សម្រាប់សាធារណជន ក្រោមអធិបតីភាព លោក លី កុសល ប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាព តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម ព្រមទាំងកញ្ញា វីរៈ បូរមី តំណាងក្រុមហ៊ុនDFC ។ វគ្គបណ្តុះបណ្តាលនេះក៏មានការអញ្ជើញចូលរួមពី ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រី និងសិក្ខាកាមចំនួន៥0នាក់។

## ប្រជុំពិភាក្សាការងារជាមួយ លោកស្រី Priya Terumalay ប្រធានប្រចាំតំបន់អាស៊ីអាគ្នេយ៍ នៃស្ថាប័ន CPA Australia




២៦.កាលពីព្រហស្បតិ៍ ៣កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៩ ខែឧសភា គ.ស.២០២៥ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក និយ័តករគណនេយ្យនិងសវនកម្ម លោក ជេន ផាត អគ្គនាយករង ថ្នាក់ដឹកនាំ និងមន្ត្រី បានចូលរួមប្រជុំពិភាក្សាជាមួយ លោកស្រី Priya Terumalay ប្រធានប្រចាំតំបន់អាស៊ីអាគ្នេយ៍នៃស្ថាប័ន CPA Australia និងក្រុមការងារនៅបន្ទប់ប្រជុំធំ ន.គ.ស. ដើម្បីពិភាក្សាលើភាពជាដៃគូនិងកិច្ចសហប្រតិបត្តិការក្នុងការលើកកម្ពស់វិជ្ជាជីវៈគណនេយ្យនិងសវនកម្មនៅកម្ពុជា។

# ប្រធានបទ "អនាគតនៃវិស័យហិរញ្ញវត្ថុ មុននិងក្រោយឆ្នាំ២០៣០ ជាមួយបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត នវានុវត្តន៍ និងនិន្នាការថ្មីៗ"



២៧.កាលពីសុក្រ ៤កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៣០ ខែឧសភា គ.ស.២០២៥ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម បានអញ្ជើញចូលរួមសុន្ទរកថាគន្លឹះ ក្នុងកម្មវិធីសន្និសីទថ្នាក់តំបន់ឆ្នាំ២០២៥ ក្រោមប្រធានបទ"អនាគតនៃវិស័យហិរញ្ញវត្ថុ មុននិងក្រោយឆ្នាំ២០៣០ ជាមួយបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត នវានុវត្តន៍ និងនិន្នាការថ្មីៗ" នៅសណ្ឋាគារសុខាភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ទី តាឃី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ដែលកម្មវិធីនេះបានរៀបចំដោយវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនកម្មកម្ពុជាសហព័ន្ធគណនេយ្យករអាស៊ាននិងសមាគមគណនេយ្យករជំនាញអន្តរជាតិ និងមានការចូលរួមពីភ្ញៀវជាតិ និងអន្តរជាតិ ព្រមទាំងគណនេយ្យករ សវនករ សាធារណជន ផងដែរ។

រៀបចំដោយ ÷ **លោក ឡាយ វិចិត្រ**

សម្របសម្រួលអត្ថបទ ÷ **កញ្ញា សុខ ណារី**

© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម